ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល. ថ្ងៃទី០៩ខែ 6 ឆ្នាំ ២០1
ក្រឡាបញ្ជី
ទ្រាំ-ចាន់ថា

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៧៦ អក
ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣
សាលក្រមលេខៈ ១១ (ជ)
ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៧៦ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានជនជាប់ចោទៈ

១/ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតភូមិ ឫស្សីស្រុក ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ន[redacted] ស្រុកអង្គស្នួល ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] ម្ដាយឈ្មោះ [redacted] មានប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។

ត្រូវបានជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិត្នោតម្ដើម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលចែងនិងផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២/ឈ្មោះ [redacted] ភិរុធ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតភូមិជ្រោយសំរោង ឃុំបាកាយ ស្រុកដូនកែវ ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ន[redacted] សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស) ម្ដាយឈ្មោះ[redacted] (រស់) មានប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន។

ដោយមានលោកស្រី[redacted]សុខា ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

ត្រូវបានជាប់ចោទពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្នោតម្ដើម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលចែងនិងផ្តន្ទាទោស តាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

Scanned by CamScanner

## ដំណើរអង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០នាទីល្ងាច ឈ្មោះ: [redacted] វណ្ណា បាននាំគ្នាផឹកស៊ីនៅផ្ទះរបស់ឈ្មោះ: [redacted] ច្រិប មានឈ្មោះ: ម៉ាប់ ឈ្មោះ: [redacted] គង្គ ឈ្មោះ: សាភយ ឈ្មោះ: រុន និងអ្នកផ្សេងជាច្រើននាក់ទៀត។ ពេលកំពុងផឹកស៊ីឈ្មោះ: [redacted] វណ្ណា បានខ្ចីម៉ូតូរបស់ឈ្មោះ: [redacted] គង្គ ដើម្បីយកសាច់ក្លែមទៅឱ្យអ្នកជិតរោងចក្រគាត់សាន ដោយ មានឧបក្មេងម្នាក់ទៅជាមួយផង បន្ទាប់មកឈ្មោះ: [redacted] វណ្ណា បានទុកក្មេងចោលនៅក្បែររោងចក្រ ហើយបានជិះម៉ូតូរបស់ឈ្មោះ: [redacted] គង្គ ទៅបាត់តែម្តង។ លុះព្រឹកឡើងឈ្មោះ: [redacted] វណ្ណា បានជិះម៉ូតូទៅជួបជាមួយឈ្មោះ: [redacted] ភ័រុធ ជាអ្នករត់ម៉ូតូឌុបដើម្បីឱ្យឈ្មោះ: ភ័រុធ ជួយយកម៉ូតូនោះទៅបញ្ចាំ ទើបឈ្មោះ: ភ័រុធ ហៅឈ្មោះ: សេរី យកម៉ូតូនោះទៅបញ្ចាំទទួលបានប្រាក់ចំនួន ៤៥០ ដុល្លាអាមេរិក។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៦៦ ដកសព ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាដំណោះស្រាយលេខ៖ ១១៦ ដកដស ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ: [redacted] វណ្ណា បានឆ្លើយបំភ្លឺថា កាលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ២ រសៀល ខ្លួន និងឈ្មោះ: [redacted] ច្រិប ឈ្មោះ: ម៉ាប់ ឈ្មោះ: [redacted] គង្គ ឈ្មោះ: សាភយ ឈ្មោះ: រុន និងអ្នកផ្សេងជាច្រើននាក់ទៀតមិនចាំឈ្មោះ: បាននាំគ្នាផឹកស្រានៅផ្ទះឈ្មោះ: [redacted] ច្រិប នៅភូមិត្នោតម្តើម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។ បន្ទាប់មកខ្លួនបានខ្ចីម៉ូតូម៉ាកស្កុបពីពណ៌ស ស៊េរី ២០១២ ពាក់ស្លាក លេខ 2L-2014 ពីឈ្មោះ: គង្គ ដោយប្រាប់គេថា យកសាច់ក្លែមទៅឱ្យគេនៅរោងចក្រ ហើយខ្លួនបានយកម៉ូតូនោះជិះដើរលេងតែម្នាក់ឯងពេញមួយយប់។ លុះព្រឹកឡើងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានទៅជួបឈ្មោះ: [redacted] ភ័រុធ ហើយខ្លួនប្រាប់ឈ្មោះ: ភ័រុធ ឱ្យជួយយកម៉ូតូនោះទៅបញ្ចាំ ដោយមិនបានប្រាប់ឈ្មោះ: ភ័រុធ ថា ម៉ូតូនោះខ្លួនខ្ចីពីគេនោះទេ បន្ទាប់មកឈ្មោះ: ភ័រុធ បានទូរសព្ទ័ហៅមិត្តភក្រ្ត គេម្នាក់ទៀតឈ្មោះ: សេរី ឱ្យជួយយកម៉ូតូនោះទៅបញ្ចាំនៅផ្សារឃ្លាំងរំសេវ បានប្រាក់ចំនួន ៤៥០ ដុល្លារអាមេរិក។ ពេលយកម៉ូតូទៅដាក់បញ្ចាំឈ្មោះ: ភ័រុធ បានជិះម៉ូតូវាម៉ាកហុងដាសេ១២៥ ទៅជាមួយខ្លួន។ ក្រោយមកឈ្មោះ: ភ័រុធ បានបបួលខ្លួន និងឌុបខ្លួន ទៅផឹកស៊ីនៅហាងរាត្រីសេកុង។ ពេលជិះតាមផ្លូវខ្លួនមិនបានចូលទិញខ្សែដៃទេ ខ្សែដៃនេះមិនមែនជារបស់ខ្លួនទេ។ ពេលផឹកស៊ីបានបន្តិច ស្រាប់តែប៉ូលីសមកចាប់ខ្លួនតែម្តង។ ខ្លួនស្នើសុំដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួនដឹងកំហុសហើយ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ: [redacted] ភ័រុធ បានឆ្លើយបំភ្លឺថា កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនជិះម៉ូតូរបស់ខ្លួនម៉ាកហុងដា C125 ស៊េរីឆ្នាំ២០០៨ ពណ៌ខ្មៅ ពាក់ស្លាកលេខ AD-5204 បិទតែរ ២០១៣ ឌុបម៉ូយទៅផ្សារឃ្លាំរំសេវ ហើយក៏បានជួប និងឈ្មោះ: [redacted] វណ្ណា ដែលស្គាល់តាមរយៈមិត្តភក្រ្ត និងធ្លាប់ផឹកស៊ីជាមួយគ្នាប៉ុន្មានថ្ងៃមុន ពេលនោះឈ្មោះ: [redacted] វណ្ណា

Scanned by CamScanner

បានសួរខ្លួនថា នៅកន្លែងណាមានគេទិញម៉ូតូ គេចង់លក់ ដោយពេលនោះគេកំពុងជិះម៉ូតូម៉ាក ស្កុបពីពណ៌ស ស៊េរី២០១២ ពាក់ផ្លាកលេខ កំពង់ធំ 1L-2014 ហើយខ្លួនបានឆ្លើយថា ខ្លួនមិនសូវស្គាល់ទេ តែខ្លួនបានទូរសព្ទ័ហៅមិត្តភក្តិខ្លួនម្នាក់ឈ្មោះ សេរី តាមរយៈទូរសព្ទ័លេខ ០១២ ៨៤០ ៥០២ ដែលគេជាអ្នកគុបជេរម៉ូតូ ពេលនោះឈ្មោះ សេរី បានប្រាប់ថាទាល់តែ ២ ទៅ ៣ម៉ោងទៀតបានទំនេរ ហើយខ្លួននិងឈ្មោះ [redacted] វណ្ណា បានបបួលគ្នាទៅផឹកស៊ីនៅអូរបែកក្អម លុះប្រហែល ២ម៉ោងក្រោយទើបឈ្មោះ សេរី ទៅដល់ ហើយបក់ដៃហៅខ្លួនទៅក្រៅ ឃើញដូច្នោះខ្លួនក៏បានប្រាប់ឈ្មោះ [redacted] វណ្ណា ឱ្យទៅជួបគេ បានបន្តិចខ្លួនក៏ដើរទៅតាមក្រោយដែរ ហើយខ្លួន បានឮឈ្មោះ សេរី ឱ្យតម្លៃម៉ូតូស្កុបពីនោះ ៤៥០ ដុល្លា បន្ទាប់ពីត្រូវថ្លៃគ្នាឈ្មោះសេរី ប្រាប់ថាគេយកទៅលក់សិនចាំបន្តិចទៀតគេយកលុយមកឱ្យ ហើយឈ្មោះសេរីបានជិះម៉ូតូ ស្កុបពីនោះចេញទៅបាត់ ដោយទុកម៉ូតូរបស់គេម៉ាកកូនទាឱ្យជាថ្នូរសម្រាប់ជិះសិន ប្រហែលមួយម៉ោងក្រោយមក ខ្លួនបានទូរសព្ទ័ទៅឈ្មោះ សេរី ទើបគេប្រាប់ថាឱ្យទៅយកលុយនោះនៅផ្សារឃ្លាំងរំសេវ ពេលទៅដល់បានយកលុយចំនួន ៤៥០ ដុល្លាអាមេរិក ពីឈ្មោះ សេរី ហើយក៏ឱ្យម៉ូតូកូនទាទៅឈ្មោះ សេរី វិញ រួចខ្លួនក៏ជិះម៉ូតូឌុបឈ្មោះ [redacted] វណ្ណា ចេញពីទីនោះ នៅតាមផ្លូវឈ្មោះ [redacted] វណ្ណា បានទិញខ្សែដៃចំនួន ០១ខ្សែ ហូតដល់ម៉ោង ៦ល្ងាច ឈ្មោះ [redacted] វណ្ណា បានបបួល ខ្លួនចូលខារ៉ាអូខេ ដោយគេថាគេជាអ្នកការ៉ាវផឹក ប្រហែល ២ម៉ោង ស្រាប់តែសមត្ថកិច្ចទៅឃាត់ ខ្លួនឈ្មោះ [redacted] វណ្ណា នៅក្រៅបន្ទប់ ឃើញដូច្នោះខ្លួនក៏ចេញទៅតាម ព្រោះមិនដឹងថាមានរឿងអី ស្រាប់តែសមត្ថកិច្ចឃាត់ទាំងរូបខ្លួនតែម្តង និងបានដកហូតយកម៉ូតូរបស់ខ្លួន ម៉ាក ហុងដា c125 ស៊េរីឆ្នាំ២០០៨ ពណ៌ខ្មៅ ពាក់ផ្លាកលេខ AD-5204 បិទតែម ២០១៣ ខ្លួនមិនបានដឹងថាម៉ូតូរបស់ឈ្មោះ [redacted] វណ្ណា ជារបស់លួចគេទេ ខ្លួនបានសួរដែរថាម៉ូតូនេះជារបស់អ្នកណាតែឈ្មោះ [redacted] វណ្ណា បានប្រាប់ថាជារបស់វា។ ចំពោះឈ្មោះ សេរី ខ្លួនធ្លាប់ស្គាល់ប្រហែល ២ ទៅ ៣ ខែហើយ ព្រោះឈ្មោះនេះជាអ្នកគុបជេរម៉ូតូ ហើយខ្លួនធ្លាប់ជូនអ្នកផ្សេងទៅលក់ និងទិញម៉ូតូពីគាត់ដើម្បីបានកំរ៉ៃម៉ុយស្បៀងខ្លះ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គង្គ បានឆ្លើយបំភ្លឺថា នៅថ្ងៃ កើតហេតុ ម៉ោងប្រហែល ៥ រសៀល ខ្លួនបានផឹកស៊ីមានគ្នាប្រហែល ១២នាក់នៅផ្ទះរបស់ ឈ្មោះ ច្រិប នៅវេលាម៉ោងប្រហែល ៥ និង ៣០នាទី ស្រាប់តែឈ្មោះ [redacted] វណ្ណា ដែលកំពុងតែ ផឹកជាមួយគ្នានោះបានខ្ចីម៉ូតូរបស់ខ្លួនម៉ាកស្កុបពីស៊េរី ២០១២ ពណ៌ស មិនចាំផ្លាកលេខ ថាជិះ យកសាច់ផ្លែទៅឱ្យមិត្តភក្តិមួយភ្លែត។ ខ្លួនក៏បានឱ្យម៉ូតូទៅឈ្មោះ [redacted] វណ្ណា ជិះទៅជាមួយក្មេងប្រុសម្នាក់ អាយុប្រហែល ៦ឆ្នាំ ហើយក៏បាត់ស្រមោលលែងឃើញមកវិញ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] វណ្ណា ដោយគាត់ឧស្សាហ៍មកផឹកស៊ីជាមួយខ្លួន ហើយខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ភ័រុធ នោះទេ។ ខ្លួនប្តឹងទាមទារសំណងពីឈ្មោះ [redacted] ណ្ណា ចំនួន ១៥០០ ដុល្លាអាមេរិក និងសូមដកពាក្យបណ្តឹងពីឈ្មោះ [redacted] ភ័រុធ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សារ៉ាយ បានឆ្លើយបំភ្លឺថា នៅថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ៣ រសៀល ស្រាប់តែឈ្មោះ [redacted] គង្គ ភេទប្រុស អាយុ ២៥ឆ្នាំ ស្នាក់នៅផ្ទះផ្ទាល់របស់ខ្លួនក្នុងភូមិបែកចាន ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល បានជិះម៉ូតូរបស់វាម៉ាកស្កុបពី ពណ៌ស ឌុបឈ្មោះ វណ្ណា ភេទប្រុស មកហៅខ្លួនឱ្យជិះម៉ូតូជាមួយ ពួកគេទៅ

Scanned by CamScanner

ជឹកស៊ីនៅផ្ទះរបស់ឈ្មោះ ច្រិប ភេទប្រុស រស់នៅភូមិត្នោតម្តើម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ពេលទៅដល់ផ្ទះរបស់ឈ្មោះ ច្រិប គឺជឹកស៊ីមានគ្នាប្រហែល ៧នាក់ តែខ្លួន ស្គាល់តែឈ្មោះ [redacted] គ័ង្គ និងវណ្ណា តែប៉ុណ្ណោះ អ្នកផ្សេងមិនស្គាល់ទេ ហើយជឹកស៊ីបានរយៈពេល ជិតមួយម៉ោង ស្រាប់តែឈ្មោះ វណ្ណា ពានខ្ចីទូរសព្ទ័របស់ខ្លួនម៉ាកស៊ាំស៊ុង ថាយកទៅតេរកមិត្ត ភក្តិរបស់គេមកជឹកជាមួយ ហើយពេលចុចទូរសព្ទ័តេពីរបីដង ឈ្មោះ វណ្ណា បានប្រាប់ខ្លួនថា មិត្ត ភក្តិរបស់គេមិនលើកទូរសព្ទ័ទេ ចាំយកម្ហូបសាច់ឆ្កែទៅឱ្យមិត្តភក្តិរបស់គេនៅកន្លែងតាបបី យ៉ែរ ពេលនោះឈ្មោះ វណ្ណា បានខ្ចីម៉ូតូរបស់ឈ្មោះ [redacted] គ័ង្គ ជិះយកម្ហូបទៅឱ្យមិត្តភក្តិព្រមទាំងខ្ចីទូរសព្ទ័របស់ខ្លួនទៅជាមួយផង ដោយថាទុកតេរកមិត្តភក្តិរបស់គេ។ ហើយឈ្មោះ វណ្ណា ជិះម៉ូតូ របស់ឈ្មោះ [redacted] គ័ង្គ ទៅដោយឌុបក្មេងប្រុសម្នាក់ទៅជាមួយផង ស្រាប់តែឈ្មោះ វណ្ណា យកម៉ូតូរបស់ឈ្មោះ [redacted] គ័ង្គ បាត់រហូតមិនឃើញជិះត្រឡប់យកមកឱ្យម្ចាស់គេវិញឡើយ ដល់ពេល ប្រហែលមួយម៉ោងក្រោយមក ស្រាប់តែឃើញក្មេងដែលជិះទៅជាមួយឈ្មោះ វណ្ណា រត់លេងទើប ខ្លួន និង ឡឹ គ័ង្គ មានការចាប់អារម្មណ៍ ក៏តេទូរសព្ទ័ទៅលេខរបស់ខ្លួនដែលឈ្មោះ វណ្ណា កាន់យកទៅនោះក៏ចូលពីរដងតែពុំលើក ហើយក៏ចុចទៅម្តងទៀតស្រាប់តែចុចមិនចូល ទើបដឹងថាឈ្មោះ វណ្ណា បានយកម៉ូតូ និងទូសព្ទ័របស់ខ្លួនទៅបាត់ ក៏នាំគ្នាដើររកតែរកមិនឃើញ។ លុះស្អែកឡើង ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួន និងឈ្មោះ គ័ង្គ បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍បែកចាន ហើយក៏នាំគ្នាដើរតាមរកឈ្មោះ វណ្ណា រហូតដល់ភ្នំពេញ ក៏បានឃើញកំពង់ជឹកស៊ីនៅហាង ឈ្មោះ ភក្រី សេកុង២ ក៏ទំនាក់ទំនងជាមួយប៉ូលីសនៅទីនោះឱ្យជួយឃាត់ឈ្មោះ វណ្ណា និងមិត្ត ភក្តិរបស់គេម្នាក់ទៀត ហើយបាននាំពួកគេយកមកបែកចានវិញតែម្តង ពេលដែលឃាត់ឈ្មោះ វណ្ណា បានសួរនាំទៅគេបានប្រាប់ថាម៉ូតូនោះលក់បាត់ហើយ នៅសល់តែទូរសព្ទ័របស់ខ្លួន ហើយឈ្មោះ វណ្ណា បានប្រគល់ទូរសព្ទ័របស់ខ្លួឱ្យមកខ្លួនវិញ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ឈ្មោះ [redacted] វណ្ណា បាននាំគ្នា ជឹកស៊ីនៅផ្ទះរបស់ឈ្មោះ ព្រួលច្រិប។ ពេលកំពុងជឹកស៊ីឈ្មោះ [redacted] វណ្ណា បានខ្ចីម៉ូតូរបស់ ឈ្មោះ ឡឹ គង្គ ជិះទៅបាត់តែម្តង។ លុះព្រឹកទៀតឈ្មោះ [redacted] វណ្ណា បានជិះម៉ូតូទៅ ជួបជាមួយឈ្មោះ សួន ភិរុធ ដើម្បីឱ្យឈ្មោះ ភិរុធ យកម៉ូតូនោះទៅបញ្ចាំ ហើយឈ្មោះ ភិរុធ យកម៉ូតូនោះទៅបញ្ចាំបានប្រាក់ចំនួន ៤៥០ ដុល្លាអាមេរិក។ ហេតុដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៦៦ ដកសព ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាបចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

Scanned by CamScanner

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយសារភាពថា កាលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ២ រសៀល ខ្លួន បានខ្ចីម៉ូតូម៉ាកស្កុបពីពណ៌ស ស៊េរី ២០១២ ពាក់ផ្លាក លេខ 2L-2014 ពីឈ្មោះ គង្គ ដោយប្រាប់គេថា យកសាច់ក្លែមទៅឱ្យគេនៅពោងចក្រ ហើយខ្លួនបានយកម៉ូតូនោះជិះដើរលេងតែម្នាក់ឯងពេញមួយយប់។ លុះព្រឹកឡើងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានទៅជួបឈ្មោះ [redacted] ភ៉ាវុធ ហើយខ្លួនប្រាប់ឈ្មោះ ភ៉ាវុធ ឱ្យជួយយកម៉ូតូនោះទៅបញ្ចាំ ដោយមិនបានប្រាប់ឈ្មោះ ភ៉ាវុធ ថា ម៉ូតូនោះខ្លួនខ្ចីពីគេនោះទេ បន្ទាប់មកឈ្មោះ ភ៉ាវុធ បានទូរស័ព្ទហៅមិត្តភក្ដិ គេម្នាក់ទៀតឈ្មោះ ស៊េរី ឱ្យជួយយកម៉ូតូនោះទៅបញ្ចាំនៅផ្សារឃ្លាំងសេរ បានប្រាក់ចំនួន ៤៥០ ដុល្លាអាមេរិក។ ពេលយកម៉ូតូទៅដាក់បញ្ចាំឈ្មោះ ភ៉ាវុធ បានជិះម៉ូតូម៉ាកហុងដា សេ១២៥ ទៅជាមួយខ្លួន។ ក្រោយមកឈ្មោះ ភ៉ាវុធ បានបបួលខ្លួន និងឌុបខ្លួន ទៅផឹកស៊ីនៅហាងរាត្រីសេកុង ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ សួន ភ៉ា វុធ, ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី។

២.ជនជាប់ចោទឈ្មោះ [redacted] ភ៉ាវុធ បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានជួបឈ្មោះ [redacted] វណ្ណា ពេលនោះឈ្មោះ [redacted] វណ្ណា បានសួរខ្លួនថា នៅកន្លែងណាមានគេទិញម៉ូតូគេចង់លក់ ដោយពេលនោះគេកំពុងជិះម៉ូតូម៉ាក ស្កុបពីពណ៌ស ស៊េរី២០១២ ពាក់ផ្លាកលេខ កំពង់ធំ 1L-2014 ហើយខ្លួនបានឆ្លើយថា ខ្លួនមិន ស្គាល់ទេ តែខ្លួនបានទូរស័ព្ទហៅមិត្តភក្ដិខ្លួនម្នាក់ឈ្មោះ ស៊េរី ក្រោយមកឈ្មោះ ស៊េរី ប្រាប់ថាឱ្យទៅមកលុយនោះផ្សារឃ្លាំងសេរ ពេលទៅដល់បានយកលុយចំនួន ៤៥០ ដុល្លាអាមេរិក ពីឈ្មោះ ស៊េរី រួចខ្លួនក៏ឌុបឈ្មោះ [redacted] វណ្ណា ចេញពីទីនោះ នៅតាមផ្លូវឈ្មោះ [redacted] វណ្ណា បានទិញ ខ្សែដៃចំនួន ០១ខ្សែ រហូតដល់ម៉ោង ៦ល្ងាច ឈ្មោះ [redacted] វណ្ណា បានបបួលខ្លួនចូលខារ៉ាអូរខេ ដោយគេថាគេជាអ្នកចាំជេក។ ខ្លួនមិនបានដឹងថា ម៉ូតូរបស់ឈ្មោះ [redacted] វណ្ណា ជារបស់លួចគេទេ ខ្លួនបានសួរដែរ ថាម៉ូតូនេះជារបស់អ្នកណា តែឈ្មោះ [redacted] វណ្ណា បានប្រាប់ថាជារបស់វា ដែលនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ។

៣.ជនជាប់ចោទឈ្មោះ [redacted] ភ៉ាវុធ ពិតជាបានដឹងច្បាស់ថា ម៉ូតូដែលឈ្មោះ [redacted] វណ្ណា យកទៅលក់ប្រាកដជាមិនមែនម៉ូតូរបស់ឈ្មោះ [redacted] វណ្ណា ព្រោះឈ្មោះ [redacted] វណ្ណា មិនមានប័ណ្ណសម្គាល់ម្ចាស់ម៉ូតូ ហើយឈ្មោះ [redacted] ភ៉ាវុធ បាននិយាយថា "ខ្លួនបានឮឈ្មោះ ស៊េរី ឱ្យតម្លៃម៉ូតូស្កុបពី ៤៥០ ដុល្លា" ដែលតម្លៃនេះថោកជាងលើសពីពាក់កណ្ដាលនៃតម្លៃម៉ូតូស្កុបពីនៅទីផ្សារ។ ជាងនេះទៅទៀត ក្រោយពេលលក់ម៉ូតូបានហើយ ឈ្មោះ [redacted] ភ៉ាវុធ បានយកលុយដែលលក់ម៉ូតូនេះទៅផឹកស៊ីជាមួយឈ្មោះ [redacted] វណ្ណា ដែលអំពើនេះច្បាស់ចាត់ទុកថាជាអំពើ ទទួលផលចោរកម្ម។

៤.តាមចម្លើយជនជាប់ចោទ, ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ពិតជាមានចេតនាទុច្ចរិតគៃបំបាត់ម៉ូតូដែលខ្ចីពីដើមបណ្ដឹងរដ្ឋប្បវេណី និងយកទៅបញ្ចាំ ដែលអំពើនេះច្បាប់ចាត់ទុកថាជា អំពើរំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

Scanned by CamScanner

៥.តាមចម្លើយជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ភ័រុធ ពិតជាទទួលផលពីការលក់ម៉ូតូរបស់ដើមបណ្តឹង ដោយបានយកលុយលក់ម៉ូតូនោះទៅផឹកស៊ីជាមួយគ្នា ដែលអំពើនេះធ្លាប់ចាត់ទុកថាជា អំពើទទួលផលចោរកម្ម តាមបញ្ញត្តិមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៦.អំពើជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិជនរងគ្រោះ សណ្តាប់ធ្នាប់សាធារណៈ ហើយជនជាប់ចោទជាជនពេញវ័យ មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៧.មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិត្នោតម្តែម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៨.មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់ឈ្មោះ [redacted] ភ័រុធ ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្នោតម្តែម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៩.ជនជាប់ចោទឈ្មោះ [redacted] ភ័រុធ គ្រាន់តែជាអ្នកជួយយកម៉ូតូទៅដាក់បញ្ចាំ, ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង, អំពើរបស់ជនជាប់ចោទមិនបង្កនូវព្យសនកម្មធ្ងន់ធ្ងរដល់សង្គម និងមិនដែលមានសាលក្រមសម្រេចផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ ឆ្នាំមុនពេលប្រព្រឹត្តអំពើនេះ គប្បីសាលាដំបូងពិចារណាពីការព្យួរទោសសម្រាប់ជនជាប់ចោទ តាមមាត្រា១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

១០.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គង្គ ប្តឹងទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទឈ្មោះ [redacted] វណ្ណា ចំនួន ១៥០០ ដុល្លាអាមេរិក តុលាការនឹងធ្វើការពិចារណាសម្រេចទៅតាមព្យសនកម្មជាក់ស្តែង។

១១.ម៉ូតូមួយគ្រឿងម៉ាក ហុងដា សេ១២៥ ស៊េរីឆ្នាំ២០០៨ ពណ៌ខ្មៅ ឡើងតែមស៊េរីឆ្នាំ ២០១៣ ពាក់ស្លាកលេខ ភ្នំពេញ ១AD-៥២០៥ និងលោហធាតុពណ៌លឿងប្រភេទខ្សែដៃមួយខ្សែ គឺជាម៉ូតូប្រើប្រាស់សម្រាប់យកម៉ូតូដែលជនជាប់ចោទឈ្មោះ [redacted] វណ្ណា គេចបាត់ជនរងគ្រោះទៅដាក់បញ្ចាំ និងបានប្រាក់នោះយកទៅទិញលោហធាតុពណ៌លឿងប្រភេទខ្សែដៃមួយខ្សែ ព្រមទាំងស៊ីផឹកជាមួយគ្នា ហេតុដូច្នេះគប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេចសេចក្តី

១/ផ្តន្ទាទោសឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ១ (មួយ) ឆ្នាំ ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិត្នោតម្តែម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២/ផ្តន្ទាទោសឈ្មោះ [redacted] ភ័រុធ ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរ ពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្នោតម្តែម ឃុំបែក ចាន



Scanned by CamScanner

ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៣/របស់វត្ថុតាងមាន: ម៉ូតូមួយគ្រឿងម៉ាក ហុងដា ស១២៥ ស៊េរីឆ្នាំ២០០៨ ពណ៌ខ្មៅ ឡើងតែមស៊េរីឆ្នាំ ២០១៣ ពាក់ស្លាកលេខ ភ្នំពេញ ១AD-៥២០៥ និងលោហធាតុពណ៌លឿង ប្រភេទខ្សែដៃមួយខ្សែ ទុកជាសម្បត្តិរដ្ឋ។

៤/បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted]វណ្ណា សងសំណងរដ្ឋប្បវេណីទៅឱ្យដើម បណ្ដឹងឈ្មោះ ឡី គង្គ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លាអាមេរិក។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ណ្ណា កំបាំងមុខជនជាប់ឈ្មោះ [redacted]ភារុធ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឡី គង្គ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]

ថ្ងៃ 27. 5. 14

[redacted]

29. 5 - 2014

[redacted]

7

Scanned by CamScanner